ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២២៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# លិខិតអនុញ្ញាតសាងសង់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្ដីពីការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីសមត្ថកិច្ច លក្ខខណ្ឌ និងនីតិវិធី ក្នុងការផ្ដល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ក្នុងគោលបំណង ដើម្បីៈ

- ធានាគុណភាព សុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិ និងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន
- ធានាការងារសាងសង់ឬរុះរើឱ្យត្រឹមត្រូវតាមបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសសំណង់ ដើម្បីរក្សាសោភណភាព បរិស្ថានល្អ និងសណ្ដាប់ធ្នាប់សាធារណៈ
- ការពារដីសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត
- ធានាគុណភាពនិងភាពត្រឹមត្រូវនៃការរៀបចំដែនដីនិងនគរូបនីយកម្ម
- បង្ការនិងទប់ស្កាត់វិវាទក្នុងការងារសាងសង់ឬរុះរើ
- បង្កើនការជឿទុកចិត្តរបស់វិនិយោគិននៅក្នុងវិស័យសំណង់ និងជំរុញទីផ្សារអចលនទ្រព្យប្រកបដោយប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនិងសង្គម។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះសំណង់គ្រប់ប្រភេទ លើកលែងតែប្រភេទសំណង់ដែលមានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៣.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១. **ការងារដី** សំដៅដល់ការងារកែប្រែរចនាសម្ព័ន្ធដីដែលបម្រើដល់ការងារសាងសង់ មានជាអាទិ៍ ការងារឈូសឆាយដី ការងារជីកដី ការងារចាក់បំពេញដី ការងារបង្ហាប់ដី ការងារពង្រឹងគុណភាពដី។

២. **ការងារដំឡើង** សំដៅដល់ការងារដំឡើងផលិតផលសំណង់ឬការងារបំពាក់បរិក្ខារសំណង់ភ្ជាប់ទៅនឹងផ្នែកនៃសំណង់ មានជាអាទិ៍គ្រឿងផ្គុំសំណង់ ជញ្ជាំង ដំបូលនៃសំណង់សម្រាប់ការប្រើប្រាស់ជាបណ្ដោះអាសន្នឬជាប់លាប់។

៣. **ការងារសាងសង់សំណង់ថ្មី** សំដៅដល់ការងារសាងសង់ដែលចាប់ផ្ដើមពីការងារដីឬការងារគ្រឹះ ការងារគ្រឿងផ្គុំ ការងារជញ្ជាំង ការងារដំឡើងរហូតដល់ការងារបង្ហើយដើម្បីបង្កើតសំណង់ថ្មីមួយ។

៤. **គ្រឿងផ្គុំសំណង់** សំដៅដល់រចនាសម្ព័ន្ធរបស់សំណង់ មានជាអាទិ៍គ្រឹះ សសរ ធ្នឹម កម្រាលខណ្ឌ ជណ្ដើរ ជញ្ជាំងទ្រទម្ងន់ គ្រឿងផ្គុំដំបូល និងគ្រឿងផ្គុំផ្សេងទៀតដែលមានមុខងារទ្រទម្ងន់។

៥. **ជញ្ជាំងទប់ដី** សំដៅដល់សំណង់ឬសិល្បការ្យ ដែលសាងសង់សម្រាប់ទប់ការរអិលដី ការបាក់ដី ឬសម្ពាធដីផ្សេងទៀតនិងដែលមិនមែនជាផ្នែកនៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ឬសំណង់ការងារទឹក។

៦. **ឋបនីយភណ្ឌ** សំដៅដល់គ្រឿងផ្គុំឬគ្រឿងឧបករណ៍ សម្ភារៈ បរិក្ខារដែលតម្កល់ទុកវត្ថុឬផលិតផលគ្រឿងឆេះដែលអាចបង្កអគ្គិភ័យផ្សេងៗជាយថាហេតុ និងដែលត្រូវទុកដាក់ឱ្យបានល្អ។

៧. **ផ្ទៃក្រឡាកម្រាលសំណង់** សំដៅដល់ផ្ទៃក្រឡាកម្រាលសំណង់ដែលធ្វើការសាងសង់។

៨. **មន្ត្រីមានសមត្ថកិច្ច** សំដៅដល់អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

៩. **មុខងារសមាសភាគសំណង់** សំដៅដល់មុខងារទាំងឡាយនៃផ្នែកនីមួយៗរបស់សំណង់ដែលផ្សំគ្នាសម្រាប់បង្កើតមុខងារប្រើប្រាស់សំណង់។

១០. **យន្តការច្រកចេញចូលតែមួយ** សំដៅដល់ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

១១. **លិខិតបញ្ជាក់អនុលោមភាព** សំដៅដល់លិខិតចេញដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដើម្បីបញ្ជាក់អំពីអនុលោមភាពនៃសំណង់ឬការងារសំណង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត។

១២. **វិញ្ញាបនបត្រប្រើប្រាស់សំណង់** សំដៅដល់លិខិតអនុញ្ញាតផ្ដល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។

១៣. **សលាកបត្រក្បាលដី** សំដៅដល់ឯកសារផ្ដល់ដោយរដ្ឋបាលសុរិយោដី ដែលមានបង្ហាញកម្មសិទ្ធិករនៃដី ទីតាំងនៃដី និយាមកាចំណុចព្រំដី និងទំហំនៃដី។

១៤. **សៀវភៅបន្ទុក** សំដៅដល់កម្រងឯកសារបច្ចេកទេសសម្រាប់បម្រើដល់ការអនុវត្តការងារសាងសង់ ឬរុះរើ មានជាអាទិ៍ផែនការការងារ សេចក្ដីណែនាំបច្ចេកទេស វិធីសាស្ត្រ និងឯកសារបច្ចេកទេសដទៃទៀត។

១៥. **សំណង់បេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រ** សំដៅដល់សំណង់ជាកេរដំណែលបន្សល់ទុកពីមនុស្សជំនាន់មុនដែលមានចរិតវិទ្យាសាស្ត្រ វប្បធម៌ ប្រវត្តិសាស្ត្រ បុរាណវិទ្យា សិល្បៈ សាសនា ដែលឆ្លុះបញ្ចាំងពីដំណាក់កាលនៃការវិវត្តរបស់អរិយធម៌ និងដែលបានចុះបញ្ជីសារពើភណ្ឌ បេតិកភណ្ឌស្របតាមច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌។

១៦. **សំណង់មិនមែនអគារ** សំដៅដល់សំណង់ដែលសាងសង់ឡើងភ្ជាប់នឹងដីឬអចលនវត្ថុដទៃទៀតសម្រាប់ទ្រទ្រង់បន្ទុកដែលត្រូវបានសិក្សាឡើងមិនមែនសម្រាប់មនុស្សស្នាក់នៅឬប្រើប្រាស់ជានិរន្តរ៍ មានជាអាទិ៍បង្គោលអង់តែនទូរសព្ទ បង្គោលអង់តែនស្ថានីយវិទ្យុឬទូរទស្សន៍ សំណង់ពាក់ព័ន្ធនឹងការគ្រប់គ្រងសកម្មភាពផ្នែកដោនស្ទ្រឹម បង្គោលអគ្គិសនី ជងទង់ ប៉ម ខ្លោងទ្វារ អាងស្ដុកទឹកខ្ពស់ពីដី ស្តូប បដិមា កន្ត្រកវិល។

១៧. **សំណង់លំនៅឋាន** សំដៅដល់សំណង់ដែលមានមុខងារប្រើប្រាស់ជាទីលំនៅអចិន្ត្រៃយ៍។

១៨. **អគារ** សំដៅដល់សំណង់ដែលសាងសង់ឡើងភ្ជាប់នឹងដីសម្រាប់ទ្រទ្រង់បន្ទុកដែលត្រូវបានសិក្សាឡើងសម្រាប់មនុស្សស្នាក់នៅឬប្រើប្រាស់ជានិរន្តរ៍ មានជាអាទិ៍សំណង់លំនៅឋាន សណ្ឋាគារ អគារការិយាល័យ មន្ទីរពេទ្យ អគារសិក្សា បណ្ណាល័យ រោងភាពយន្ត សារមន្ទីរ សាលមហោស្រព ផ្សារ រោងចក្រ ស្ថានីយអ្នកដំណើរ។

១៩. **អាជ្ញាធរមានសមត្ថកិច្ច** សំដៅដល់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

២០. **ឯកសារបច្ចេកទេស** សំដៅដល់គម្រោងប្លង់ស្ថាបត្យកម្ម គម្រោងប្លង់គ្រឿងផ្គុំសំណង់ គម្រោងប្លង់រុះរើ គម្រោងប្លង់ប្រព័ន្ធមេកានិក អគ្គិសនី ឬទឹក លិខិតបញ្ជាក់អនុលោមភាព វិញ្ញាបនបត្រប្រើប្រាស់សំណង់ ឯកសារសិក្សាភូគព្ភសាស្ត្រ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ឯកសារសិក្សាសមិទ្ធិលទ្ធកម្ម សៀវភៅបន្ទុកនៃការងារសាងសង់ និងគម្រោងប្លង់បច្ចេកទេសដទៃទៀត។

## ជំពូកទី២

## សមត្ថកិច្ច

**មាត្រា៤ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងសំណង់គ្រប់ប្រភេទ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចផ្ដល់លិខិតអនុញ្ញាតសាងសង់ និងលិខិតអនុញ្ញាតរុះរើចំពោះសំណង់ឬការងារ ដូចខាងក្រោម៖

- សំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបលើសពី៣ ០០០(បីពាន់)ម៉ែត្រក្រឡា
- ការងារសាងសង់ឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់ដែលមានស្រាប់ ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់បូកផ្ទៃក្រឡាកម្រាលសំណង់ថ្មី សរុបលើសពី៣ ០០០ (បីពាន់)ម៉ែត្រក្រឡា
- អគារដែលមានកម្ពស់ខ្ពស់ជាង១១(ដប់មួយ)ជាន់ឡើងទៅរួមទាំងជាន់ផ្ទាល់ដី
- សំណង់ដែលមានជាន់ក្រោមដីក្នុងជម្រៅជ្រៅជាង៥(ប្រាំ)ម៉ែត្រ
- ជញ្ជាំងទប់ដីដែលមានកម្ពស់ខ្ពស់ជាង៥(ប្រាំ)ម៉ែត្រ
- ឋបនីយភណ្ឌដែលអាចបង្កគ្រោះថ្នាក់ដោយអគ្គិភ័យដូចជាស្ថានីយឬដេប៉ូស្តុក លក់ ឬចែកចាយប្រេងឥន្ធនៈ ឧស្ម័ន ឬផលិតផលតេលសិលាដទៃទៀត ពោងឬស៊ីទែនស្តុកប្រេងឥន្ធនៈ ឧស្ម័ន សារធាតុងាយឆេះ ឬផលិតផលតេលសិលាដទៃទៀត និងរោងជាងដែលមានផលិតផលងាយឆេះ
- អាងតម្កល់ឬស្តុកទឹកដែលមានកម្ពស់ខ្ពស់ជាង១៥(ដប់ប្រាំ)ម៉ែត្រ ឬមានចំណុះលើសពី៥០(ហាសិប) ម៉ែត្រគូប
- សំណង់សម្រាប់បម្រើវិស័យកីឡា ទេសចរណ៍ និងវប្បធម៌ មានជាអាទិ៍ពហុកីឡដ្ឋាន ទីលានវាយកូនហ្គោល ទីលានកីឡាប្រណាំង សួនកម្សាន្ត អាងហែលទឹក សារមន្ទីរ សាលមហោស្រព សាលសន្និសីទ រោងភាពយន្ត
- សំណង់នៅក្នុងតំបន់ការពារបរិស្ថានធម្មជាតិ បេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ ឬតំបន់ការពារផ្សេងទៀត
- អគារ ប៉ម ឬសំណង់នៅក្នុងស្ថានីយអ្នកដំណើរតាមរថយន្ត ស្ថានីយអយស្ម័យយាន កំពង់ផែ អាកាសយានដ្ឋាន និងស្ថានីយរ៉ាវីអគ្គិសនី ដែលមិនមែនជាផ្នែកនៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ឬផ្នែកនៃសំណង់ការងារទឹក
- សំណង់អគារ ប៉ម ឬខ្លោងទ្វារនៅតាមច្រកទ្វារអន្តរជាតិ
- បង្គោលអង់តែនទូរសព្ទនិងបង្គោលអង់តែនស្ថានីយវិទ្យុឬទូរទស្សន៍
- សំណង់មិនមែនអគារដទៃទៀតដែលមានកម្ពស់ខ្ពស់ជាង៣០(សាមសិប)ម៉ែត្រ។

**មាត្រា៥ .-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដោយមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្តជាសេនាធិការ មានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតអនុញ្ញាតរុះរើ ចំពោះសំណង់ឬការងារ ដូចខាងក្រោម៖

- សំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ៣ ០០០(បីពាន់)ម៉ែត្រក្រឡា និងមានកម្ពស់ទាបជាងឬស្មើ១១(ដប់មួយ)ជាន់រួមទាំងជាន់ផ្ទាល់ដី ដោយគ្មានឬមានជាន់ក្រោមដីក្នុង

ជម្រៅរាក់ជាងឬស្មើ៥(ប្រាំ)ម៉ែត្រ លើកលែងសំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

- ការងារសាងសង់ឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់ដែលមានស្រាប់ ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់ បូកផ្ទៃក្រឡាកម្រាលសំណង់ថ្មីសរុបលើសពី៥០០(ប្រាំរយ) ម៉ែត្រក្រឡា និងតិចជាងឬស្មើ៣ ០០០(បីពាន់)ម៉ែត្រក្រឡា
- ជញ្ជាំងទប់ដីដែលមានកម្ពស់ទាបជាងឬស្មើ៥(ប្រាំ)ម៉ែត្រ
- របងថ្មឬបេតុងដែលមានកម្ពស់ខ្ពស់ជាង៣(បី)ម៉ែត្រ
- សំណង់មិនមែនអគារដទៃទៀតដែលមានកម្ពស់ទាបជាងឬស្មើ៣០(សាមសិប)ម៉ែត្រ។

**មាត្រា៦ .-**

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាសេនាធិការ មានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតអនុញ្ញាតរុះរើ ចំពោះសំណង់ឬការងារដូចខាងក្រោម៖

- សំណង់លំនៅឋានដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ៥០០(ប្រាំរយ)ម៉ែត្រក្រឡានិងមានកម្ពស់ទាបជាងឬស្មើ៤(បួន)ជាន់រួមទាំងជាន់ផ្ទាល់ដី និងគ្មានជាន់ក្រោមដី
- ការងារសាងសង់សំណង់លំនៅឋានឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់លំនៅឋានដែលមានស្រាប់ ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់បូកផ្ទៃក្រឡាកម្រាលសំណង់ថ្មីសរុបលើសពីទំហំផ្ទៃក្រឡាកម្រាលសំណង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ និងតិចជាងឬស្មើ៥០០(ប្រាំរយ)ម៉ែត្រក្រឡា
- របងថ្មឬបេតុងដែលមានកម្ពស់ទាបជាងឬស្មើ៣(បី)ម៉ែត្រ។

**មាត្រា៧ .-**

រាជរដ្ឋាភិបាលឬស្ថាប័នតំណាងដែលបានទទួលសិទ្ធិប្រទាន មានសមត្ថកិច្ចផ្តល់ការអនុញ្ញាតឱ្យសាងសង់ឬរុះរើ ចំពោះសំណង់ដូចខាងក្រោម៖

- សំណង់ដែលជាការសម្ងាត់របស់ជាតិ មានជាអាទិ៍សំណង់សម្រាប់បោះពុម្ពរូបិយបណ្ណ តម្កល់ និងរក្សាទុករូបិយវត្ថុ
- សំណង់សម្រាប់បម្រើដល់សន្តិសុខជាតិនិងការការពារជាតិ មានជាអាទិ៍សំណង់លេណដ្ឋាន ឃ្លាំងស្តុកអាវុធនិងគ្រឿងយុទ្ធភណ្ឌ និងសំណង់បម្រើដល់ការប្រយុទ្ធ។

## ជំពូកទី៣
## គោលការណ៍ទូទៅនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់

**មាត្រា៨ .-**

រាល់ការសាងសង់ឬរុះរើ ត្រូវមានលិខិតអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ច លើកលែងតែការងារមួយចំនួនដែលបានកំណត់នៅក្នុងអនុក្រឹត្យនេះ។

រាល់ចម្លើយបដិសេធរបស់អាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ច ចំពោះការស្នើសុំលិខិតអនុញ្ញាត ត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងមានបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់។

ការមិនសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាត ក្នុងរយៈពេលដែលបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវចាត់ទុកថាអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ច បានផ្តល់ការអនុញ្ញាតដល់ម្ចាស់សំណើដោយតុណ្ហីភាព។

សិទ្ធិនិងកាតព្វកិច្ចដែលទទួលបានពីលិខិតអនុញ្ញាតដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវផ្ទេរទៅឱ្យកម្មសិទ្ធិករថ្មីឬអ្នកកាន់កាប់ថ្មីនៃសំណង់ នៅពេលមានការផ្ទេរកម្មសិទ្ធិនៃដីឬសិទ្ធិកាន់កាប់ដី និង/ឬការផ្ទេរកម្មសិទ្ធិនៃសំណង់ឬគម្រោងសាងសង់នោះត្រឹមត្រូវតាមគោលការណ៍និងនីតិវិធីជាធរមាន។

**មាត្រា៩ .-**

ក្នុងករណីអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចសម្រេចបដិសេធផ្តល់លិខិតអនុញ្ញាត អាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចនោះ ត្រូវចេញលិខិតជូនដំណឹងនិងតម្រូវឱ្យម្ចាស់សំណើមកទទួលយកសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតរបស់ខ្លួនវិញ។

ក្នុងករណីម្ចាស់សំណើមិនមកទទួលយកសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតរបស់ខ្លួនក្នុងរយៈពេល ៣០(សាបសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង អាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចអាចសម្រេចមិនរក្សាទុកសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតនោះបាន។

**មាត្រា១០ .-**

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ត្រូវយកទៅដាក់នៅ៖

១. ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់លិខិតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២. អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត សម្រាប់លិខិតផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

៣- ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់លិខិតផ្ដល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

បង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត អាចផ្ដល់ជូនម្ចាស់សំណើ តែក្នុងករណីសំណុំឯកសារស្នើសុំនោះមានលក្ខណៈគ្រប់គ្រាន់។

ក្នុងករណី សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត មានលក្ខណៈមិនត្រឹមត្រូវ យន្តការច្រកចេញចូលតែមួយ ត្រូវស្នើជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើឱ្យធ្វើការកែតម្រូវ។

កំលុងពេលនៃការកែតម្រូវសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត មិនត្រូវបានរាប់បញ្ចូលក្នុងបរិបថនៃការសម្រេចលើពាក្យស្នើសុំឡើយ។

**មាត្រា១១ .-**

អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ត្រូវបង់កម្រៃសេវា។

កម្រៃសេវាពិនិត្យនិងផ្ដល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ត្រូវបង់នៅពេលទទួលបង្កាន់ដៃទទួលពាក្យស្នើសុំនិងមិនអាចប្រគល់ជូនម្ចាស់សំណើវិញឡើយ ទោះក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចសម្រេចបដិសេធផ្ដល់ការអនុញ្ញាតជូនម្ចាស់សំណើក៏ដោយ។

កម្រៃសេវាពិនិត្យនិងផ្ដល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាតដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

កម្រៃសេវាពិនិត្យនិងផ្ដល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាតដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១២ .-**

សំណុំឯកសារស្ដីពីលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ត្រូវតម្កល់ទុករយៈពេលយ៉ាងតិច ១៥(ដប់ប្រាំ)ឆ្នាំនៅ៖

- អគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ចំពោះលិខិតអនុញ្ញាតផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំពោះលិខិតអនុញ្ញាតផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

សំណុំឯកសារស្តីពីលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ដែលគម្រោងប្លង់ស្ថាបត្យកម្មមានតម្លៃពិសេសផ្នែកស្ថាបត្យកម្ម ត្រូវតម្កល់ទុកជាអចិន្ត្រៃយ៍។

## ជំពូកទី៤
## លិខិតអនុញ្ញាតសាងសង់

**មាត្រា១៣ .-**

មានតែកម្មសិទ្ធិករនៃដីនិងអ្នកដែលបានកាន់កាប់ដីស្របច្បាប់ ទើបអាចអនុញ្ញាតឱ្យសាងសង់សំណង់នៅលើដីនោះបាន។

ការងារសាងសង់ មិនអាចអនុញ្ញាតនៅលើដីដែលកំពុងមានវិវាទអំពីសិទ្ធិកាន់កាប់បានឡើយ។

**មាត្រា១៤ .-**

ការងារសាងសង់ក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយដើម្បីជួយសង្គ្រោះឬការពារអាយុជីវិត ឬបង្ការមិនឱ្យមានការប៉ះពាល់ឬខូចខាតធ្ងន់ធ្ងរដល់សុខភាពឬទ្រព្យសម្បត្តិក្នុងភាពអាសន្ន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតជាមុនឡើយ ទោះបីការងារសាងសង់នោះអនុវត្តនៅលើដីដែលកំពុងមានវិវាទអំពីសិទ្ធិកាន់កាប់ក៏ដោយ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នឬគ្រោះមហន្តរាយត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលត្រូវបានសាងសង់ក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយ ត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់តាមលក្ខខណ្ឌនិងនីតិវិធីជាធរមាន។

**មាត្រា១៥ .-**

សំណង់ដែលការងារសាងសង់មិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ មានដូចខាងក្រោម៖

- សំណង់អគារផ្ទាល់ដីដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ១២(ដប់ពីរ)ម៉ែត្រក្រឡា និងមានកម្ពស់ទាបជាងឬស្មើ៥(ប្រាំ)ម៉ែត្រ
- លំនៅឋានធ្វើពីឈើ ផ្ទះថ្មក្រោមឈើលើដោយមានកម្រាលខណ្ឌធ្វើពីឈើ ផ្ទះគៀមធ្វើពីឈើឬថ្មនៅទីជនបទឬស្រែចម្ការ ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ១០០(មួយរយ)

ម៉ែត្រក្រឡា មានកម្ពស់ទាបជាងឬស្មើ៤(បួន)ម៉ែត្រ និងមិននៅក្នុងតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ

- សំណង់មិនមែនបេតុងដែលសាងសង់ផ្ទាល់ដីសម្រាប់ប្រើប្រាស់ជាបណ្តោះអាសន្ន មានជាអាទិ៍ បង្គោល ដងទង់ វេទិកា រោង តូប ឬគ្រឿងផ្គុំដទៃទៀតសម្រាប់ប្រារព្ធពិធីផ្សេងៗ
- សំណង់នៅក្នុងបរិវេណវត្តអារាមនៃព្រះពុទ្ធសាសនាដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ២០(ម្ភៃ)ម៉ែត្រក្រឡានិងមានកម្ពស់ទាបជាងឬស្មើ១២(ដប់ពីរ)ម៉ែត្រ
- របងដែលមិនធ្វើអំពីថ្មឬបេតុង។

**មាត្រា១៦ .-**

ការងារកែប្រែដែលមិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្រទ្រង់បន្ទុក គ្រឿងផ្គុំសំណង់ និងសោភណភាពខាងក្រៅ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ មិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ឡើយ មានជាអាទិ៍៖

- ការប្តូរពណ៌ផ្ទៃកខាងក្នុង
- ការប្តូរទ្រង់ទ្រាយផ្នែកខាងក្នុងនៃសំណង់ ដូចជាបង្កាន់ដៃសុវត្ថិភាព ពិតានដែលមិនធ្វើពីបេតុងដែក ជញ្ជាំងខណ្ឌបន្ទប់ដែលមិនទ្របន្ទុក
- ការប្តូរមុខងារសមាសភាគសំណង់ដែលមិនបង្កើនបន្ទុកលើគ្រឿងផ្គុំសំណង់និងក្នុងគោលដៅមិនមែនអាជីវកម្ម។

**មាត្រា១៧ .-**

មុននឹងធ្វើការសាងសង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាត ម្ចាស់សំណង់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនទៅមេឃុំឬចៅសង្កាត់នៃទីតាំងដែលសំណង់នោះស្ថិតនៅ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងជាមុនអំពីការងារសាងសង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១៨ .-**

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវធ្វើជាភាសាខ្មែរ និងត្រូវមានភ្ជាប់ឯកសារបញ្ជាក់អំពីកម្មសិទ្ធិឬសិទ្ធិកាន់កាប់ស្របច្បាប់នៃដីដែលសំណង់តាំងនៅ សលាកបត្រក្បាលដី គម្រោងប្លង់ស្ថាបត្យកម្ម និងឯកសារបច្ចេកទេសផ្សេងទៀតសម្រាប់បម្រើឱ្យការងារសាងសង់។

**មាត្រា១៩ .-**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ក្នុងរយៈពេលយ៉ាងយូរ៤៥(សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលច្រកចេញចូលតែមួយ

នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញបង្កាន់ដៃទទួលពាក្យស្នើសុំនោះ។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលយ៉ាងយូរ២៥(ម្ភៃប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ចេញបង្កាន់ដៃទទួលពាក្យស្នើសុំនោះ។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចេញបង្កាន់ដៃទទួលពាក្យស្នើសុំនោះ។

**មាត្រា២០ .-**

លិខិតអនុញ្ញាតសាងសង់ អស់សុពលភាពក្នុងករណីដែលការដ្ឋានសំណង់មិនបានចាប់ផ្តើមដំណើរការក្នុងរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតសាងសង់នោះ។

ក្នុងករណីម្ចាស់សំណង់បានទទួលលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ រយៈពេលនៃសុពលភាពលិខិតអនុញ្ញាតសាងសង់ ត្រូវចាប់ផ្តើមរាប់ឡើងវិញគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតបើកការដ្ឋានសំណង់នោះ។

អាជ្ញាធរមានសមត្ថកិច្ច អាចបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់បានតែមួយដងគត់។

លក្ខខណ្ឌនៃការបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់មានដូចខាងក្រោម៖

- ការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ត្រូវបានធ្វើមកអាជ្ញាធរមានសមត្ថកិច្ចតាមរយៈយន្តការច្រកចេញចូលតែមួយ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃមុនថ្ងៃផុតសុពលភាពលិខិតអនុញ្ញាតសាងសង់
- គ្មានការកែប្រែគម្រោងប្លង់ស្ថាបត្យកម្មដើមនៃលិខិតអនុញ្ញាតសាងសង់
- មិនទាន់មានការចាប់ផ្តើមសាងសង់នៅការដ្ឋានសំណង់។

រយៈពេលសម្រាប់សម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់។

**មាត្រា២១ .-**

បែបបទនិងបរិបទនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បែបបទនិងបរិបទនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្រោយការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៥
## លិខិតអនុញ្ញាតជួសជុល

**មាត្រា២២ .-**

ការងារជួសជុលសំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ ត្រូវមានលិខិតអនុញ្ញាតជួសជុលជាមុន។

**មាត្រា២៣ .-**

ការងារជួសជុលដែលមិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្រទ្រង់ គ្រឿងផ្គុំសំណង់ ទ្រង់ទ្រាយដើម និងសោភណភាពខាងក្រៅ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ មិនតម្រូវឱ្យមានលិខិតអនុញ្ញាតជួសជុលឡើយ មានជាអាទិ៍៖

- ការជួសជុលផ្នែកខាងក្នុងដែលមានការខូចខាត ឬការផ្លាស់ប្តូរចំណែកចាស់ទ្រុឌទ្រោមដែលអាចបង្កនូវគ្រោះថ្នាក់ជាយថាហេតុ
- ការកោសលាបនិង/ឬការបូកបន្ថែមផ្នែកខាងក្នុងអគារ
- ការកែលម្អនិង/ឬការប្តូរពិតានដែលមិនធ្វើពីបេតុងដែក
- ការកែលម្អនិង/ឬការប្តូរឬការបំពាក់បរិក្ខារនិងផលិតផលសំណង់នៅខាងក្នុង មានជាអាទិ៍ការ៉ូក្រដាសបិទជញ្ជាំង ជញ្ជាំងកញ្ចក់ សន្លឹកទ្វារ សន្លឹកបង្អួច ម៉ាស៊ីនត្រជាក់
- ការកែលម្អនិង/ឬការប្តូរឬការបំពាក់បរិក្ខារសំណង់ មានជាអាទិ៍បរិក្ខារបន្ទប់ទឹក គ្រឿងបន្លាស់ជណ្តើរយន្ត បណ្តាញខ្សែទូរគមនាគមន៍ និងបរិក្ខារអគ្គិសនី មានជាអាទិ៍ខ្សែភ្លើង ខ្សែអុបទិក អំពូលកង្ហារ។

**មាត្រា២៤ .-**

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតជួសជុល ត្រូវមានភ្ជាប់ឯកសារបញ្ជាក់អំពីកម្មសិទ្ធិលើសំណង់ លិខិតអនុញ្ញាតសាងសង់ គម្រោងប្លង់ស្ថាបត្យកម្ម គម្រោងប្លង់គ្រឿងផ្គុំសំណង់ វិញ្ញាបនបត្រប្រើប្រាស់សំណង់ និងឯកសារបច្ចេកទេសផ្សេងទៀតសម្រាប់បម្រើឱ្យការងារជួសជុល។

**មាត្រា២៥ .-**

រយៈពេលសម្រាប់សម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុល ត្រូវកំណត់ដូចខាងក្រោម៖

១. យ៉ាងយូរ២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតជួសជុលដោយច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតជួសជុលផ្តល់ដោយអគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២. យ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុលដោយអង្គភាពច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតជួសជុលផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

៣- យ៉ាងយូរ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុលដោយការិយាល័យច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតជួសជុលផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

**មាត្រា២៦ .-**

លិខិតអនុញ្ញាតជួសជុលអស់សុពលភាពក្នុងករណីដែលការដ្ឋានសំណង់មិនបានចាប់ផ្តើមដំណើរការក្នុងរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតជួសជុលនោះ។

លិខិតអនុញ្ញាតជួសជុល អាចបន្តសុពលភាពបានតែមួយដងគត់។

លក្ខខណ្ឌនៃការបន្តសុពលភាពលិខិតអនុញ្ញាតជួសជុលមានដូចខាងក្រោម៖

- ការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតជួសជុលត្រូវបានធ្វើ តាមរយៈយន្តការច្រកចេញចូលតែមួយ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃមុនថ្ងៃផុតសុពលភាពលិខិតអនុញ្ញាតជួសជុល
- គ្មានការកែប្រែគម្រោងប្លង់ស្ថាបត្យកម្មឬគម្រោងប្លង់គ្រឿងផ្គុំសំណង់ដើមនៃលិខិតអនុញ្ញាតជួសជុល
- មិនទាន់មានការចាប់ផ្តើមជួសជុលនៅការដ្ឋានសំណង់។

ការងារជួសជុលត្រូវបានចាត់ទុកថាបានចាប់ផ្តើម កាលណាការងារដំបូងត្រូវបានអនុវត្តចំពោះផ្នែកណាមួយនៃសំណង់។

ការដ្ឋានសំណង់ដែលបានចាប់ផ្តើមដំណើរការជួសជុល ប៉ុន្តែបានផ្អាកសកម្មភាពទៅវិញលើសពី៦(ប្រាំមួយ)ខែ ត្រូវមានលិខិតបន្តសុពលភាពលិខិតអនុញ្ញាតជួសជុល មុននឹងបន្តដំណើរការជួសជុល។

រយៈពេលសម្រាប់សម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុល ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការស្នើសុំបន្តសុពលភាពនៃលិខិតអនុញ្ញាតជួសជុល។

**មាត្រា២៧ .-**

មុននឹងធ្វើការជួសជុលដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាត ម្ចាស់សំណង់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនទៅមេឃុំឬចៅសង្កាត់នៃទីតាំងដែលសំណង់នោះស្ថិតនៅ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងជាមុនអំពីការងារជួសជុលដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៨ .-**

បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតជួសជុលដោយអគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។

បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតជួសជុលដោយអភិបាលនៃគណៈអភិបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្រោយការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

# ជំពូកទី៦
## លិខិតអនុញ្ញាតរុះរើ

**មាត្រា២៩ .-**

ការងាររុះរើសំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ ត្រូវមានលិខិតអនុញ្ញាតរុះរើជាមុន។

**មាត្រា៣០ .-**

ការស្នើសុំលិខិតអនុញ្ញាតរុះរើ ត្រូវធ្វើដោយម្ចាស់សំណង់។

សំណង់ដែលកំពុងមានវិវាទអំពីកម្មសិទ្ធិ មិនអនុញ្ញាតឱ្យរុះរើឡើយ។

**មាត្រា៣១ .-**

ការងាររុះរើសំណង់ក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយដើម្បីជួយសង្គ្រោះឬការពារអាយុជីវិតឬបង្ការមិនឱ្យមានការប៉ះពាល់ឬខូចខាតធ្ងន់ធ្ងរដល់សុខភាពឬទ្រព្យសម្បត្តិក្នុងភាពអាសន្ន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតជាមុនឡើយ ទោះបីសំណង់នោះកំពុងមានវិវាទអំពីកម្មសិទ្ធិក៏ដោយ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរក្រោយពីស្ថានភាពអាសន្នឬគ្រោះមហន្តរាយត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលបានរុះរើក្នុងភាពអាសន្នឬគ្រោះមហន្តរាយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា៣២ .-**

មុននឹងធ្វើការរុះរើដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាត ម្ចាស់សំណង់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនទៅមេឃុំឬចៅសង្កាត់នៃទីតាំងដែលសំណង់នោះស្ថិតនៅ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងជាមុនអំពីការងាររុះរើដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៣ .-**

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតរុះរើ ត្រូវមានភ្ជាប់ឯកសារបញ្ជាក់អំពីកម្មសិទ្ធិនៃសំណង់ គម្រោងប្លង់ស្ថាបត្យកម្ម គម្រោងប្លង់រុះរើ និងឯកសារបច្ចេកទេសផ្សេងទៀតសម្រាប់បម្រើឱ្យការងាររុះរើ។

**មាត្រា៣៤ .-**

បញ្ញត្តិស្ដីពីរយៈពេលនៃការសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះរយៈពេលនៃការសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតរុះរើ។

**មាត្រា៣៥ .-**

បញ្ញត្តិស្ដីពីលក្ខខណ្ឌសុពលភាព ការស្នើសុំបន្តសុពលភាព និងការអនុញ្ញាតឱ្យបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះលក្ខខណ្ឌសុពលភាព ការស្នើសុំបន្តសុពលភាព និងការអនុញ្ញាតឱ្យបន្តសុពលភាពលិខិតអនុញ្ញាតរុះរើ។

ការបន្តសុពលភាពលិខិតអនុញ្ញាតរុះរើ មិនត្រូវមានការកែប្រែគម្រោងប្លង់រុះរើនៃសំណង់ដែលបានកំណត់ក្នុងលិខិតអនុញ្ញាតរុះរើដើមឡើយ។

**មាត្រា៣៦ .-**

បែបបទនិងបរិបថនៃការផ្ដល់លិខិតអនុញ្ញាតរុះរើដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បែបបទនិងបរិបថនៃការផ្ដល់លិខិតអនុញ្ញាតរុះរើដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោយការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៧
## លិខិតអនុញ្ញាតបើកការដ្ឋានសំណង់

**មាត្រា៣៧ .-**

ការចាប់ផ្ដើមដំណើរការការងារសាងសង់សំណង់ថ្មី ការងារកែប្រែ ការងារដំឡើង និងការងាររុះរើ ត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ជាមុនស្របតាមលិខិតអនុញ្ញាតសាងសង់ឬរុះរើសំណង់នោះ។

ការដ្ឋានសំណង់ដែលបានចាប់ផ្ដើមដំណើរការ ប៉ុន្តែបានផ្អាកសកម្មភាពទៅវិញ លើសពី១(មួយ)ឆ្នាំ ត្រូវមានលិខិតបន្តសុពលភាពលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ មុននឹងបន្តដំណើរការសាងសង់ឬរុះរើ។

**មាត្រា៣៨ .-**

ការងារសាងសង់សំណង់ថ្មីត្រូវបានចាត់ទុកថាបានចាប់ផ្ដើមដំណើរការ នៅពេលដែលការងារដីឬការងារគ្រឹះដំបូងត្រូវបានអនុវត្ត។ ការងារកែប្រែត្រូវបានចាត់ទុកថាបានចាប់ផ្ដើម កាលណាផ្នែកណាមួយនៃសំណង់ឬបរិក្ខារសំណង់ឬផលិតផលសំណង់ត្រូវបានផ្លាស់ប្ដូរ។ ការងារដំឡើងត្រូវបានចាត់ទុកថាបានចាប់ផ្ដើម កាលណាផ្នែកណាមួយនៃបរិក្ខារសំណង់ឬផលិតផលសំណង់ ត្រូវបានភ្ជាប់ទៅនឹងសំណង់។

ការងាររុះរើត្រូវបានចាត់ទុកថាបានចាប់ផ្ដើមដំណើរការ នៅពេលដែលផ្នែកដំបូងនៃសំណង់ត្រូវបានដកឬរើចេញ។

ក្នុងករណីអាជ្ញាធរមានសមត្ថកិច្ចមិនសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ឬរុះរើក្នុងរយៈពេលដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ម្ចាស់សំណើអាចដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ចាប់ពីថ្ងៃផុតរយៈពេលកំណត់នោះ។

**មាត្រា៣៩ .-**

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់សម្រាប់ការងារសាងសង់ ត្រូវមានភ្ជាប់លិខិតអនុញ្ញាតសាងសង់ គម្រោងប្លង់គ្រឿងផ្គុំសំណង់ ឯកសារសិក្សាភូគព្ភសាស្ត្រ សៀវភៅបន្ទុកនៃការងារ

សាងសង់ កិច្ចសន្យាម៉ៅការសាងសង់ ឯកសារបច្ចេកទេសផ្សេងទៀតសម្រាប់បម្រើឱ្យការងារសាងសង់ និង វិញ្ញាបនបត្រធានារ៉ាប់រង ឬឯកសារបញ្ជាក់អំពីការចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន ជាមួយក្រុមហ៊ុនធានារ៉ាប់រង។

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់សម្រាប់ការងាររុះរើ ត្រូវមានភ្ជាប់លិខិត អនុញ្ញាតសាងសង់ លិខិតអនុញ្ញាតរុះរើ គម្រោងប្លង់គ្រឿងផ្គុំសំណង់ គម្រោងប្លង់រុះរើ សៀវភៅបន្ទុកនៃ ការងាររុះរើ កិច្ចសន្យាម៉ៅការសាងសង់ ឯកសារបច្ចេកទេសផ្សេងទៀតសម្រាប់បម្រើឱ្យការងាររុះរើ និង វិញ្ញាបនបត្រធានារ៉ាប់រង ឬឯកសារបញ្ជាក់អំពីការចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន ជាមួយក្រុមហ៊ុនធានារ៉ាប់រង។

ក្នុងករណីសំណង់ត្រូវបានអនុញ្ញាតឱ្យសាងសង់ឬរុះរើដោយតុណ្ហីភាព សំណុំឯកសារស្នើសុំលិខិត អនុញ្ញាត បើកការដ្ឋានសំណង់សម្រាប់ការងារសាងសង់ឬរុះរើ ត្រូវមានភ្ជាប់បង្កាន់ដៃទទួលពាក្យស្នើសុំ លិខិតអនុញ្ញាតសាងសង់ឬរុះរើ និងឯកសារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។

ត្រូវបានរាប់បញ្ចូលជាឯកសារបច្ចេកទេស លិខិតឯកភាពជាគោលការណ៍របស់ក្រសួង ស្ថាប័ន ឬ រដ្ឋបាលថ្នាក់ក្រោមជាតិតាមការកំណត់របស់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**មាត្រា៤០ .-**

រយៈពេលសម្រាប់សម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ត្រូវកំណត់ដូច ខាងក្រោម៖

១. យ៉ាងយូរ២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលសំណុំឯកសារស្នើសុំលិខិត អនុញ្ញាតបើកការដ្ឋានសំណង់ដោយច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ផ្តល់ ដោយអគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២. យ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំលិខិត អនុញ្ញាតបើកការដ្ឋានសំណង់ដោយអង្គភាពច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតបើកការដ្ឋាន សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

៣. យ៉ាងយូរ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាត បើកការដ្ឋានសំណង់ដោយការិយាល័យច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

**មាត្រា៤១ .-**

លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ អស់សុពលភាពក្នុងករណីណាមួយដូចខាងក្រោម៖

- ការដ្ឋានសំណង់មិនបានចាប់ផ្តើមដំណើរការក្នុងរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិត អនុញ្ញាតបើកការដ្ឋានសំណង់នោះ

- ការដ្ឋានសំណង់បានផ្អាកដំណើរការរយៈពេលលើសពី១(មួយ)ឆ្នាំ
- លិខិតអនុញ្ញាតសាងសង់ឬរុះរើអស់សុពលភាព ត្រូវបាននិរាករឬប្រកាសមោឃភាពដោយអាជ្ញាធរមានសមត្ថកិច្ចឬដោយតុលាការ។

លិខិតអនុញ្ញាតបើកការដ្ឋានសំណង់អាចបន្តសុពលភាពបានតែមួយដងគត់។

លក្ខខណ្ឌនៃការបន្តសុពលភាពលិខិតអនុញ្ញាតបើកការដ្ឋានសំណង់មានដូចខាងក្រោមៈ

- ការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវបានធ្វើតាមរយៈយន្តការច្រកចេញចូលតែមួយ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃមុនថ្ងៃផុតសុពលភាពលិខិតអនុញ្ញាតបើកការដ្ឋានសំណង់
- គ្មានការកែប្រែគម្រោងប្លង់ស្ថាបត្យកម្ម គម្រោងប្លង់គ្រឿងផ្គុំសំណង់ ឬគម្រោងប្លង់រុះរើដើមនៃលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតរុះរើ ឬលិខិតអនុញ្ញាតបើកការដ្ឋានសំណង់។

**មាត្រា៤២ .-**

បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ដោយអគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោយការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៨
## លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬលិខិតបន្តសុពលភាពលិខិតអនុញ្ញាត សម្រាប់គម្រោងអភិវឌ្ឍន៍អចលនវត្ថុ

**មាត្រា៤៣ .-**

ការផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ក្នុងគម្រោងអភិវឌ្ឍន៍អចលនវត្ថុ ត្រូវគោរពតាមលក្ខខណ្ឌនិងនីតិវិធីសម្រាប់សំណង់ទូទៅដែរ។

ការស្នើសុំលិខិតអនុញ្ញាតសាងសង់ក្នុងគម្រោងអភិវឌ្ឍន៍អចលនវត្ថុ ត្រូវមានលិខិតអនុញ្ញាតអភិវឌ្ឍដីផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចជាមុន។

ការសាងសង់ក្នុងគម្រោងអភិវឌ្ឍន៍អចលនវត្ថុ អាចអនុញ្ញាតឱ្យធ្វើឡើងតាមដំណាក់កាលស្របតាមផែនការ ដូចមានកំណត់ក្នុងលិខិតអនុញ្ញាតអភិវឌ្ឍដី។

**មាត្រា៤៤ .-**

ការស្នើសុំលិខិតអនុញ្ញាតសាងសង់ដោយបំបែកជាគម្រោងតូចៗនៃគម្រោងអភិវឌ្ឍនៃបណ្ដុំផ្ទះល្វែង ឬគម្រោងបណ្ដុំលំនៅឋានក្នុងគោលដៅអាជីវកម្មដែលមានម្ចាស់សំណង់តែមួយ មានម្ចាស់ដីតែមួយ និងស្ថិតនៅលើក្បាលដីតែមួយ ត្រូវហាមឃាត់។

**មាត្រា៤៥ .-**

គម្រោងសាងសង់បណ្ដុំផ្ទះល្វែង ឬបណ្ដុំលំនៅឋានក្នុងគោលដៅអាជីវកម្មដែលស្ថិតនៅលើក្បាលដីតែមួយ ត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ជាមុន មុននឹងអនុញ្ញាតឱ្យធ្វើការបំបែកក្បាលដី។

គម្រោងសាងសង់អគារសហកម្មសិទ្ធិក្នុងគោលដៅអាជីវកម្មដែលស្ថិតនៅលើក្បាលដីតែមួយ ត្រូវអនុវត្តការងារសាងសង់គ្រឿងឆ្អឹងសំណង់អគារទាំងមូលមួយរយភាគរយ និងបានរៀបចំខណ្ឌជញ្ជាំង ចំណែកឯកជនរួចរាល់តាមប្លង់អនុញ្ញាត មុននឹងអនុញ្ញាតឱ្យធ្វើការបំបែកជាចំណែកឯកជន។

## ជំពូកទី៩

## ការប្ដឹងតវ៉ា

**មាត្រា៤៦ .-**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្ដីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច ឬមន្ត្រីមានសមត្ថកិច្ចដូចមានចែងក្នុងអនុក្រឹត្យនេះ មានសិទ្ធិតវ៉ាទៅអាជ្ញាធរ ឬមន្ត្រីមានសមត្ថកិច្ចដែលបានចេញសេចក្ដីសម្រេចនោះ ឬទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬទៅតុលាការតាមនីតិវិធីដូចមានចែងក្នុងច្បាប់ស្ដីពីសំណង់និងបទប្បញ្ញត្តិដទៃទៀតជាធរមាន។

**មាត្រា៤៧ .-**

បុគ្គលដែលរងការខូចខាត ឬមានការបារម្ភជាក់ស្ដែងថានឹងរងការខូចខាតដោយសារការអនុវត្តសិទ្ធិ ឬកាតព្វកិច្ចរបស់បុគ្គលណាម្នាក់ដូចមានកំណត់ក្នុងលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ អាចធ្វើសំណើទៅគណៈកម្មការដោះស្រាយវិវាទសំណង់ដើម្បីធ្វើការសម្រុះសម្រួលតាមនីតិវិធីជាធរមាន។

## ជំពូកទី១០

## ទណ្ឌកម្ម

**មាត្រា៤៨ .-**

បុគ្គលដែលក្លែងបន្លំឯកសារ ឬផ្ដល់ព័ត៌មានមិនពិតដល់អាជ្ញាធរ ឬមន្ត្រីមានសមត្ថកិច្ចដើម្បីទទួលបានលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ដូចមានចែងក្នុងអនុក្រឹត្យនេះ ឬក្លែងបន្លំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬលិខិតបន្ត

សុពលភាពលិខិតអនុញ្ញាត ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

**មាត្រា៤៩ .-**

អ្នករាជការសាធារណៈមានសមត្ថកិច្ចដែលមិនទទួលពិនិត្យសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ឬបដិសេធផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ដោយគ្មានមូលហេតុត្រឹមត្រូវ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌ តាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី១១
## អន្តរប្បញ្ញត្តិ

**មាត្រា៥០ .-**

លិខិតបទដ្ឋាននិងគោលការណ៍ណែនាំរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ពាក់ព័ន្ធនឹងការផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ដែលអនុវត្តមុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវមានអានុភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋាននិងគោលការណ៍ណែនាំថ្មីមកជំនួស។

លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ដែលបានផ្តល់ជូនម្ចាស់សំណង់មុនអនុក្រឹត្យនេះចូលជាធរមាន នៅបន្តសុពលភាពរហូតថ្ងៃផុតសុពលភាពលិខិតអនុញ្ញាតទាំងនោះ។

**មាត្រា៥១ .-**

ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ដែលបានដាក់នៅយន្តការច្រកចេញចូលតែមួយមុនអនុក្រឹត្យនេះចូលជាធរមាន អាជ្ញាធរមានសមត្ថកិច្ចនិងមន្ត្រីមានសមត្ថកិច្ច ត្រូវបន្តដំណើរការពិនិត្យនិងសម្រេចរហូតដល់ចប់នីតិវិធី។ ក្នុងករណីនេះ អាជ្ញាធរមានសមត្ថកិច្ចនិងមន្ត្រីមានសមត្ថកិច្ចត្រូវអនុវត្តគោលការណ៍ឬលក្ខខណ្ឌទាំងឡាយដូចមានចែងក្នុងអនុក្រឹត្យនេះដែលផ្តល់ប្រយោជន៍ដល់ម្ចាស់សំណើ។

**មាត្រា៥២ .-**

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតជួសជុលសំណង់ដែលបានសាងសង់រួចមុនអនុក្រឹត្យនេះចូលជាធរមានដោយមានឬគ្មានលិខិតអនុញ្ញាតសាងសង់ ត្រូវភ្ជាប់លិខិតបិទការដ្ឋានសំណង់ ឬវិញ្ញាបនបត្រប្រើប្រាស់សំណង់ និងឯកសារបច្ចេកទេសផ្សេងទៀតដូចមានចែងក្នុងអនុក្រឹត្យនេះ។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា៥៣ .-**

អនុក្រឹត្យលេខ៨៦ អនក្រ.បក. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១ រោច ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ